# ការបោះឆ្នោត និងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**សៃមិន គ្រូស័រ**

**ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៣**

*ប្រែសម្រួលដោយ ភួង ច័ន្ទប្រណិត*

តើការបោះឆ្នោតមានន័យយ៉ាងដូចម្តេចសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និង អតីតខ្មែរក្រហម?

នៅពេលដែលខ្ញុំកំពុងសរសេរអត្ថបទនេះ ខ្ញុំនៅតែមិនទាន់ច្បាស់នៅឡើយទេថាតើនរណានឹងបន្ត ដឹកនាំប្រទេសកម្ពុជា ដោយសារទាំងគណបក្សប្រជាជនកម្ពុជារបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន និងគណបក្សសង្គ្រោះជាតិរបស់លោក សម រង្ស៊ី នៅតែអះអាងពីជ័យជម្នះក្នុងការបោះឆ្នោតកាលពី ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ រៀងៗខ្លួន។ លទ្ធផលនៃការប្រឈមមុខដាក់គ្នានេះ ទំនងជានឹងជះ ឥទ្ធិពលយ៉ាងសំខាន់ដល់អនាគតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

គណបក្សសង្គ្រោះជាតិមិនមានចំណាត់ការស៊ីសង្វាក់គ្នាទេនៅនិងអតីតកាលរបស់ប្រទេសកម្ពុជា និងរបបកម្ពុជាប្រជាធិបតេយ្យ ។ ម្យ៉ាងគណបក្សសង្គ្រោះជាតិមានគោលនយោបាយជាយូរមកហើយ ថា អតីតកម្មាភិបាលខ្មែរក្រហមមួយចំនួនដែលបច្ចុប្បន្នកំពុងកាន់តំណែងក្នុងរដ្ឋាភិបាលគួរតែត្រូវបាន យកទៅជំនុំជម្រះ ។ ប៉ុន្តែម្យ៉ាងវិញទៀត ប្រធានស្តីទីគណបក្សសង្គ្រោះជាតិ លោក កឹម សុខា ដែល ត្រូវបានថតជាសំឡេងដោយបានអះអាងថា អំពើឃោរឃៅដែលបានប្រព្រឹត្តិឡើងនៅមន្ទីរស-២១ត្រូវ បានរៀបចំឡើងជាឆាកដោយវៀតណាម ។ ក្រោយមក លោក កឹម សុខា បានប្រានចោលបទអត្ថា ធិប្បាយបែបនេះដោយបកស្រាយថា បទអត្ថាធិប្បាយនោះត្រូវបានប្រឌិតឡើង និងក្រឡៃខុសពីពាក្យ សម្តីពិតប្រាកដរបស់គាត់ ហើយគាត់បានបកស្រាយវិញថា ខ្មែរក្រហមបានរៀបចំគុកទួលស្លែងជាឆាក ល្ខោនមិនមែនវៀតណាមជាអ្នករៀបចំនោះឡើយ ។

យើងអាចប្រមើលមើលឃើញថា ការកើនឡើងនៃអំណាចរបស់គណបក្សសង្គ្រោះជាតិ នឹងនាំ ទៅរកការកើនឡើងនៃការគាំទ្រតុលាការ ប្រសិនបើគណបក្សសង្គ្រោះជាតិទទួលជ័យជម្នះ ឬកើនកៅអី នៅរដ្ឋសភាជាតិ ។

ផ្ទុយទៅវិញ ប៉ុន្មានឆ្នាំថ្មីៗនេះ គណបក្សប្រជាជនកម្ពុជារបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ចង់ ឲ្យតុលាការបញ្ចប់សំណុំរឿងរបស់ខ្លួនដោយមិនចោទប្រកាន់នរណាបន្ថែមទៀតឡើយ ។ ក្នុងឆ្នាំ២០១០ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រាប់អគ្គលេខាធិការអង្គការសហប្រជាជាតិ លោក បាន គីមូន ថា

គាត់រំពឹងថា សំណុំរឿង០០២នឹងក្លាយជាសំណុំរឿងចុងក្រោយដែលត្រូវបានជំនុំជម្រះនៅតុលាការ ។ ដូច្នេះហើយ លទ្ធផលនៃការបោះឆ្នោត នាពេលបច្ចុប្បន្ន ទំនងជានឹងជះឥទ្ធិពលយ៉ាងសំខាន់ ដល់ជំហររបស់រដ្ឋាភិបាលលើសំណុំរឿង០០៣និង០០៤ ។

វាមិនមែនគ្រាន់តែជាជំហររបស់រដ្ឋាភិបាលមួយមុខនោះទេ ដែលការបោះឆ្នោតនឹងក្លាយជាចំណោទបញ្ហានោះ ប៉ុន្តែសហគមន៍អន្តរជាតិក៏ជាចំណោទបញ្ហាមួយដែរ ដែលជាម្ចាស់ជំនួយដ៏សំខាន់ដែលអាចធ្វើឲ្យកិច្ចដំណើរការតុលាការបន្តទៅទៀតបាន ។ ការមិនគាំទ្ររបស់ម្ចាស់ជំនួយគឺជាបញ្ហាយ៉ាងសំខាន់សម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ខណៈដែលជំនួយថវិការរបស់អន្តរជាតិនៅតែជាបញ្ហាគន្លឹះដល់ការគាំទ្របុគ្គលិកទាំងផ្នែកជាតិនិងអន្តរជាតិ ។ ប្រការនេះមានន័យថា ប្រសិនបើរដ្ឋាភិបាលកម្ពុជាបាត់បង់ជំនួយពីសហគមន៍អន្តរជាតិ តុលាការអាចប្រឈមមុខទៅនឹងការបន្តនិរន្តរភាពរបស់ខ្លួនកាន់តែខ្លាំងជាងមុន ។ មុនការបោះឆ្នោតប្រព្រឹត្តឡើង សមាជិកសភាជាតិអាមេរិក បានសង្កត់ធ្ងន់លើសារៈសំខាន់នៃការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅក្នុងប្រទេសកម្ពុជា និងលទ្ធភាពនៃលក្ខខណ្ឌដែលឆ្លើយតបទៅនឹងជំនួយនាពេលអនាគត ។ ចាប់តាំងពីពេលនោះមក សហរដ្ឋអាមេរិក បានអំពាវនាវឲ្យមានការស៊ើបអង្កេតលើភាពមិនប្រក្រតីក្នុងការបោះឆ្នោត ។

ប្រសិនបើគណបក្សប្រជាជនកម្ពុជាបន្តព្រងើយកន្តើយនឹងការអំពាវនាវ ហើយបដិសេធមិនស៊ើបអង្កេតលើការចោទប្រកាន់អំពីភាពមិនប្រក្រតី ដែលមានទម្រង់ជាប្រព័ន្ធក្នុងអំឡុងការបោះឆ្នោតកម្ពុជា នឹងក្លាយជាប្រទេសដែលមិនសូវមានចំណាប់អារម្មណ៍សម្រាប់ម្ចាស់ជំនួយអន្តរជាតិដែលនឹងធ្វើឲ្យមានការប៉ះពាល់ដល់ជំនួយថវិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

**-ចប់-**